# គម្រោងពង្រីកប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតនិរោធ (ដំណាក់កាលទី៣)
# របស់
# រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ

## ព័ត៌មានអំពីគម្រោង

### ១. សាវតាគម្រោង

- **ម្ចាស់គម្រោង៖** រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ
- **ម្ចាស់កម្ចីហិរញ្ញប្បទាន៖** កម្ចីអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលជប៉ុន តាមរយៈទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA)
- **ប្រភេទគម្រោង៖** គម្រោងអភិវឌ្ឍន៍របស់រដ្ឋ
- **សមត្ថភាពប្រព្រឹត្តកម្មទឹកស្អាតដំណាក់កាលទី៣៖** ២០០.០០០ ម$^{៣}$/ថ្ងៃ
- **ទំហំផ្ទៃដីពង្រីករបស់អាងប្រព្រឹត្តកម្មទឹកស្អាត៖** ៥,២០ ហិកតា
- **តំបន់សេវាកម្ម៖** ៧ ខណ្ឌ ក្នុងរាជធានីភ្នំពេញ និង ៣ ស្រុក/ក្រុង ក្នុងខេត្តកណ្តាល
- **ប្រវែងបណ្តាញបំពង់ទុយោមេនាំទឹកស្អាត៖** ៨,៥២ គីឡូម៉ែត្រ
- **ប្រវែងបណ្តាញបំពង់ចែកចាយទឹកស្អាត៖** ១.៣២០ គីឡូម៉ែត្រ
- **រយៈពេលសាងសង់៖** ឆ្នាំ ២០២៦-ឆ្នាំ ២០៣០

### ២. ទីតាំងគម្រោង

រដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញនឹងធ្វើការពង្រីកប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតនិរោធ (ដំណាក់កាលទី៣) ដែលមានទីតាំងស្ថិតនៅក្នុងរោងចក្រប្រព្រឹត្តកម្មទឹកស្អាតនិរោធ ក្នុងភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ សម្រាប់ផ្គត់ផ្គង់ទឹកស្អាតដល់តំបន់សេវាកម្មនៅក្នុងរាជធានីភ្នំពេញ ដែលមានដូចជា ខណ្ឌសែនសុខ ខណ្ឌទួលគោក ខណ្ឌបឹងកេងកង ខណ្ឌមានជ័យ ខណ្ឌដង្កោ ខណ្ឌពោធិ៍សែនជ័យ និងខណ្ឌច្បារអំពៅ។ ដោយឡែកសម្រាប់នៅក្នុងខេត្តកណ្តាលវិញមាន ក្រុងតាខ្មៅ ស្រុកកណ្តាលស្ទឹង និងស្រុកស្អាង។




ផែនទី ១៖ បង្ហាញពីទីតាំងគម្រោង

## ៣. ហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់តំបន់សិក្សា

គម្រោងពង្រីកប្រព័ន្ធប្រព្រឹត្តកម្មទឹកស្អាតនិរោធ (ដំណាក់កាលទី៣) នឹងធ្វើការបង្ហូរសំណល់រាវតាមប្រព័ន្ធលូបង្ហូរសំណល់រាវ (ខ្សែពណ៌ក្រហម) ដែលមានស្រាប់ចេញពីទីតាំងគម្រោងចូលទៅក្នុងទន្លេបាសាក់ ដែលមានបង្ហាញនៅក្នុងរូបភាពខាងក្រោម៖




រូបភាព ១៖ បង្ហាញពីទីតាំងប្រព័ន្ធលូបង្ហូរសំណល់រាវចេញពីក្នុងទីតាំងគម្រោង

## ៤. ការជួបពិគ្រោះយោបល់ជាសាធារណៈ ឬជនពាក់ព័ន្ធ

ក្រុមសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នឹងធ្វើការជួបប្រជុំពិគ្រោះយោបល់ជាសាធារណៈ ឬជនពាក់ព័ន្ធ។ សម្រាប់កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈនេះនឹងមានការចូលរួមពី អ្នកតំណាងក្រសួងសាធារណការ និងដឹកជញ្ជូន អាជ្ញាធរមូលដ្ឋានភូមិ-ឃុំពាក់ព័ន្ធ និងប្រជាពលរដ្ឋរស់នៅក្បែរទីតាំងគម្រោង ដែលអាចទទួលរងផលប៉ះពាល់ពីសកម្មភាពគម្រោង។ ការជួបប្រជុំពិគ្រោះយោបល់ធ្វើឡើងក្នុងមានគោលបំណងដូចខាងក្រោម៖

- បង្ហាញពីលទ្ធផលនៃការប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី១
- បង្ហាញពីលទ្ធផលនៃការសិក្សាលើគុណភាពទឹកលើដី និងសំណល់រាវ និងផលប៉ះពាល់នៃការបង្ហូរសំណល់រាវចូលទៅក្នុងទឹកទន្លេបាសាក់
- ដើម្បីប្រមូលធាតុចូល គំនិតយោបល់ ឬក៏អនុសាសន៍ល្អៗបន្ថែមទៀតពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ទៅលើទិដ្ឋភាពផ្សេងៗ និងបញ្ហាមួយចំនួនដែលទាក់ទងជាមួយនឹងសកម្មភាពគម្រោង។

កិច្ចប្រជុំពិគ្រោះយោបល់ជាសាធារណៈលើកទី២ នេះនឹងត្រូវធ្វើឡើងនៅចន្លោះថ្ងៃទី២៤ ខែកុម្ភៈ ដល់ ៧ ខែមីនា ឆ្នាំ២០២៥ ក្រោមការសម្របសម្រួលពីអាជ្ញាធរមូលដ្ឋានសង្កាត់។ ក្រុមការងារនឹងបញ្ជាក់បន្ថែមថ្ងៃកំណត់ជាក់ស្តែងបន្ទាប់ពីទទួលបានការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋានសង្កាត់។